**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~~~

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

តុលាការកំពូល
~~~~~
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៤
ចុះថ្ងៃទី០៥ខែមិថុនាឆ្នាំ២០២០
សាលដីកា
លេខ ៣៣៣ "IV"
ចុះថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០២០

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ដោយសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោមៈ

១.ឯកឧត្តម ... ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២.ឯកឧត្តម ... ជាចៅក្រម
៣.ឯកឧត្តម ... ជាចៅក្រម
៤.ឯកឧត្តម ... ជាចៅក្រម
៥.លោកជំទាវ ... ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជីសវនាការ**

កញ្ញា ....

**តំណាងមហាអយ្យការ**

ឯកឧត្តម ... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **របរ** ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ០២ក្រ៉ ៕ "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានៈ

១.ឈ្មោះ **របរ** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ កន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ ...(រស់) ម្តាយឈ្មោះ ... (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិលោក **មបរ**

២.ឈ្មោះ **លថរ** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិមេសប្រច័ន្ទ ឃុំមេសប្រច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួន នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ..(រស់) ម្តាយឈ្មោះ ...(រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។

៣.ឈ្មោះ ***សសវ*** ហៅ រាជ អាយុ៣០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ...(រស់) ម្ដាយឈ្មោះ ...(រស់) ប្រពន្ធឈ្មោះ ***លថរ*** កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចរាជធានីភ្នំពេញ បានកើតមានករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើង ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ ***ករន*** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ ***សសវ*** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ ***លថរ*** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនដែកឆែរឃើញមានថ្នាំញៀន រួមទាំងជញ្ជីងសម្រេប់ថ្លឹងគ្រឿងញៀនចំនួន១។ នៅពេលឃាត់ខ្លួនជនជាប់ចោទខាងលើ បានឆ្លើយសារភាព ថ្នាំញៀន គឺពួកខ្លួនទិញពីឈ្មោះ **ណ** ហៅ ខ្មៅ ភេទប្រុស និងឈ្មោះ **ត** រួចសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ ចំពោះជនជាប់ចោទ ១.ឈ្មោះ ***ករន*** ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ២.ឈ្មោះ ***សសវ*** ហៅ រាជ អាយុ៣០ឆ្នាំ ៣.ឈ្មោះ ***របរ*** ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ៤.ឈ្មោះ ***លថរ*** ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចពិនិត្យទឹកនោមឃើញមានសារធាតុញៀន។

បានឃើញសាលក្រមលេខ៧១៥ក្រ១១(យ១)ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ មានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១.ផ្ដន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ ***ករន*** ហៅ **ហ៊ីម** ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ
ដាក់ពន្ធនាគារកំណត់ចំនួន ៥(ប្រាំ)ឆ្នាំ ។
ខ.ឈ្មោះ ***សសវ*** ហៅ **រាជ** ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ
គ.ឈ្មោះ ***របរ*** ហៅ **ម៉ាប់** ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ
ឃ.ឈ្មោះ***លថរ*** ហៅ **ដា** ភេទស្រី អាយុ២០ឆ្នាំ ជនជាតិខ្មែរ
ដាក់ពន្ធនាគារកំណត់ចំនួន ៦(ប្រាំមួយ)ឆ្នាំ ។

ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុចាប់យកដែលត្រូវរឹបអូសមាន៖

១.ស្រោមសំបុត្រពណ៌សមានក្រាមថ្លាទម្ងន់២,៨១ក្រាម (ពីរក្បៀសប៉ែតសិបមួយក្រាម) ជារបស់ជនជាប់ចោទឈ្មោះ **ករន**។

២.ស្រោមសំបុត្រពណ៌ស មានក្រាមថ្លាទម្ងន់ ២៥,០៣ក្រាម (ម្ភៃប្រាំក្បៀសសូន្យបីក្រាម) ជារបស់ជនជាប់ចោទឈ្មោះ **សសរ**, ឈ្មោះ**របរ** និងឈ្មោះ **លថរ** ។

៣.ទូរស័ព្ទ០៣គ្រឿង ម៉ាកហូវ៉ាយ (HUAWEI) និងពីរគ្រឿងទៀត ម៉ាកណូគាខ្មៅចុចពិលចំនួន ០១គ្រឿង ពណ៌សចំនួន០១គ្រឿង។

៤.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១

៥. ក្រដាសអាលុយមីញ៉ូមចំនួន០១ដុំតូច ដបសម្រាប់ដក់គ្រឿងញៀនចំនួន០៤ និងដែកកេះចំនួន០១។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ **ករន** ហៅ **ហ៊ីម** ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ **សសរ** ហៅ **រាជ** ភេទប្រុស អាយុ៣០ឆ្នាំ, ឈ្មោះ **របរ** ហៅ **ម៉ាប់** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ **លថរ** ហៅ **ដា** ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៖៦៧៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ឈ្មោះជនជាប់ចោទឈ្មោះ **សសរ** ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ៧១៥ក្រ១១(ឃ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៖ ៦៧៦ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ លោកស្រី... ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ **សសរ** ឈ្មោះ **របរ** ហៅ ម៉ាប់ ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ៧១៥ក្រ១១(ឃ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៖៦៨១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ **របរ** ហៅ ម៉ាប់ ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ៧១៥ក្រ១១(ឃ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៖៧៣៧ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ **លថរ** ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ៧១៥ក្រ១១(ឃ១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០២ ក្រ៉ ៉ញ៉ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ឈ្មោះ***សសវ*** និងលោកស្រី ... ជាមេធាវីការពារឲ្យឈ្មោះ ***សសវ***, ឈ្មោះ ***របរ***ហៅ ម៉ាប់ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់ឈ្មោះ **លថរ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៖៧១៥ ៉ឃ១៉ ក្រ៉ចុះថ្ងៃទី២១ ខែ៩ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១ក.ខ.ឃ ត្រង់ចំណុច ៉ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៦ឆ្នាំ៉ ត្រូវកែប្រែមកជា ៉ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំវិញ៉។

៣.បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ ***សសវ***, ឈ្មោះ ***របរ*** និងឈ្មោះ **លថរ**។

៤.សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

ទុកសិទ្ធិឲ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ ***របរ*** ដែលប្តឹងសាទុក្ខចំពោះសាសដីកាព្រហ្មទណ្ឌលេខ០២ ក្រ៉ ៉ញ៉ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា ចម្លើយរបស់ជនជាប់ចោទ ***របរ*** នៅតុលាការអង្គសេចក្តី និងនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ថាខ្លួនធ្លាប់មកលេងបន្ទប់ឈ្មោះ រាជ និងសង្សា បានបីដងហើយឈ្មោះ រាជ ធ្លាប់ឲ្យយកគ្រឿងញៀនទៅលក់បានពីរដង មួយកញ្ចប់តម្លៃ ១០ដុល្លារ ហើយគាត់ឲ្យលុយលើ ៦ ០០០ រៀល ទៅ ១០ ០០០រៀល។ ដូចនេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទមិនមានមូលហេតុដូចក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

## ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឲ្យ

១.បណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ ***របរ*** ទុកជាត្រឹមត្រូវតាមកំណត់ច្បាប់ តែបដិសេធចោលដោយខុសទៅនឹងគតិច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០២ ក្រ៉ ៉ញ៉ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

-ជនជាប់ចោទឈ្មោះ ***របរ*** បានឆ្លើយថា ខ្លួនមានអាយុ២៣ឆ្នាំ ខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ដោយសារតែ ខ្លួនពុំដឹងរឿងអ្វីនោះទេ។ គេឃាត់ខ្លួននៅម៉ោង៣ជាង តែថ្ងៃណាខ្លួនពុំចាំទេ គេឃាត់ខ្លួននៅផ្ទះសំណាក់បឹងលាភ ហើយឃាត់ខ្លួនបានមនុស្សបីនាក់មានឈ្មោះ ***សសរ*** ឈ្មោះ **លថរ** និងខ្លួន។ នៅថ្ងៃកើតហេតុ ខ្លួនមករកការងារនៅភ្នំពេញនេះ ហើយមកលេងឈ្មោះ ***សសរ*** នៅផ្ទះសំណាក់បឹងលាភ តែខ្លួនមិនបានដឹងថា នៅក្នុងបន្ទប់នោះមានគ្រឿងញៀននោះទេ ទាល់តែដល់ពេលគេមកចាប់ខ្លួនទើបគេដឹងថាបន្ទប់នោះមានគ្រឿងញៀន ខ្លួនស្គាល់តែឈ្មោះ ***សសរ*** តែម្នាក់ទេ។ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ គេបង្ខំឲ្យខ្លួនសារភាព ទទួលស្គាល់ ខ្លួនភ័យពេកក៏សារភាពតាមគេទៅថា យកគ្រឿងញៀនពីអ្នកនេះអ្នកនោះ ប៉ុន្តែខ្លួនមិនស្គាល់នោះទេ។ ខ្លួនសំណូមពរឲ្យតុលាការកំពូលមេត្តា លើកលែងការចោទប្រកាន់ខ្លួនផង។

-លោក **មបរ** មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ***របរ*** បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនបានដាក់សេចក្តីសន្និដ្ឋានការពារជូនតុលាការកំពូលរួចហើយ ខ្លួនសុំសន្និដ្ឋានបន្ថែមថា កូនក្តីខ្លួនបានឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ព្រោះកូនក្តីខ្លួនមកភ្នំពេញ ដើម្បីរកការងារធ្វើហើយក៏ទៅលេងឈ្មោះ ***សសរ*** ក៏ត្រូវគេចាប់ខ្លួនតែម្តង។ សាលាដំបូង និងសាលាឧទ្ធរណ៍ បានចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនតែកូនក្តីខ្លួនបានឆ្លើយរួចហើយថា គេបង្ខិតបង្ខំឲ្យឆ្លើយទេ ចម្លើយសារភាពដែលបង្ខិតបង្ខំឲ្យឆ្លើយពុំចាត់ទុកថាជាបានការនោះទេ ព្រោះវាបាត់នូវធាតុផ្សំនៃបទល្មើស ព្រោះបើបាត់ធាតុផ្សំនៃបទល្មើស វាមានន័យថា វាមិនមែនជាបទល្មើសជួញដូរនោះទេ ហើយក៏មិនមានបទល្មើសកើតឡើង និងមិនមានបទល្មើសព្រហ្មទណ្ឌដែរ ចម្លើយសារភាពដែលឈ្មោះ ***សសរ*** និងឈ្មោះ **លថរ** បានឆ្លើយ របស់របរដែលរកឃើញក្នុងបន្ទប់នោះ មិនមែនជារបស់កូនក្តីខ្លួននោះទេ គឺជារបស់អ្នកផ្សេងទៀត ដែលចម្លើយនេះអាចបញ្ជាក់ថា កូនក្តីខ្លួនមិនបានប្រព្រឹត្តទេ។ ខ្លួនសំណូមពរឲ្យតុលាការកំពូលមេត្តា ពិនិត្យពិចារណាទៅតាមមាត្រា៤៤០ នៃក្រមព្រហ្មទណ្ឌ ។

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានបន្ថែមថា ក្រោយពីស្តាប់ការសួរដេញដោលនាពេលនេះរួចមក ឃើញថាជនជាប់ចោទបានឆ្លើយបដិសេធជាច្រើនលើកច្រើនមកហើយថា ខ្លួនមិនបានប្រព្រឹត្តនោះទេ ដូច្នេះវាហាក់ដូចជាមិនទាន់ច្បាស់លាស់នៅឡើយ និងមានវិមតិសង្ស័យ សំណូមពរពិចារណាសាជាថ្មី។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **របរ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាការ និងមាត្រា៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា នៅក្នុងរឿងក្តីនេះមានជនជាប់ចោទចំនួន០៤នាក់ ប៉ុន្តែមានជនជាប់ចោទឈ្មោះ **របរ** ម្នាក់ដែលបានប្តឹងសាទុក្ខប្រឆាំងនឹងសាលដីការបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ។ ដូច្នេះ តុលាការកំពូល ធ្វើការពិចារណាតែក្នុងក្របខណ្ឌបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ**របរ** ម្នាក់ប៉ុណ្ណោះ។

៣.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញដែលយល់ឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទជួញដូរ និងប្រើប្រាស់សារធាតុញៀនដោយខុសច្បាប់ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ដោយសំអាងទៅលើចម្លើយរបស់ជនជាប់ចោទឈ្មោះ **របរ** នៅដំណាក់កាលនគរបាលយុត្តិធម៌នោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយ ព្រោះថាតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ **របរ** នៅដំណាក់កាលនគរបាលយុត្តិធម៌ថា កន្លងមក ខ្លួនធ្លាប់ទៅលេងនៅបន្ទប់ស្នាក់នៅរបស់ឈ្មោះ **សសរ** ហៅ រាជ បីដងមកហើយ ត្រូវបានឈ្មោះ **សសរ** ហៅ រាជ ប្រើឲ្យយកគ្រឿងញៀនទៅលក់ឲ្យគេបានចំនួន ០២ដង ពេលលក់បានលុយយកឲ្យឈ្មោះ **សសរ** ហៅ រាជ ទាំងអស់ ហើយឈ្មោះ **សសរ** ហៅ រាជ បានឲ្យប្រាក់ឈ្នួលពីការលក់គ្រឿងញៀនមកខ្លួនចំនួន ៥ ០០០រៀល ទៅ ១០ ០០០រៀល និងឲ្យគ្រឿងញៀនប្រើប្រាស់មួយចំនួន ឃើញថាចម្លើយនេះពាក់ព័ន្ធនឹងរឿងហេតុដែលបានកើតឡើងកន្លងមក ប៉ុន្តែអង្គហេតុនៃការចោទប្រកាន់ និងផ្តន្ទាទោស គឺកើតឡើងនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ <u>នេះមិនអាចយកអង្គហេតុមុនមកកំណត់ពិរុទ្ធភាពលើជនជាប់ចោទ ដែលបានប្រព្រឹត្តនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បានទេ</u>។ ដូច្នេះ តុលាការអង្គហេតុ គប្បីធ្វើការស្រាវជ្រាវឲ្យបានច្បាស់លាស់ទៅលើអង្គហេតុនៃការចោទប្រកាន់ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ **របរ** នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នេះ ។ ម្យ៉ាងទៀត ជនជាប់ចោទបានឆ្លើយបញ្ជាក់ថានៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ខ្លួនគ្រាន់តែបានមកបន្ទប់ជួលរបស់ឈ្មោះ **សសរ** ហៅ រាជ ព្រឹក ហើយក៏ត្រូវសមត្ថកិច្ចចុះឆែកឆេរបន្ទប់ និងឃាត់ខ្លួនតែម្តងនៅពេលរសៀល ដែលជាប់ចោទឈ្មោះ **របរ** អះអាងថា មិនបានចូលរួមប្រព្រឹត្តទេ ដែលគប្បីធ្វើការពិនិត្យ និងស្រាវជ្រាវបន្ថែមឲ្យបានច្បាស់លាស់មុននឹងកំណត់ពិរុទ្ធភាព។

៤.យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៧១៥ "ឃ១" ក្រ॥ ចុះថ្ងៃទី២១ ខែ៩ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១ ក.ខ.ឃ ត្រង់ចំណុច "ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៦ឆ្នាំ" ត្រូវកែប្រែមកជា "ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំវិញ" ជាការសម្រេចសេចក្តីដោយមានការភាន់ច្រឡំ ព្រោះថាចំណុចទី១.ក នៃសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ:៧១៥ "ឃ១" ជនជាប់ចោទឈ្មោះ **ករន** ហៅ ហ៊ីម ត្រូវសាលាដំបូង សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំ ហើយ ហើយជនជាប់ចោទរូបនេះ ក៏មិនបានធ្វើបណ្តឹងឧទ្ធរណ៍សាលក្រមរបស់សាលា

ដំបូងដែរ ដែលគប្បីសាលាឧទ្ធរណ៍ពិចារណា និងសម្រេចឲ្យបានត្រឹមត្រូវឡើងវិញ ឃើញថាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទមានមូលហេតុត្រឹមត្រូវតាមបញ្ញត្តិមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥.យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ០២ ក្រ॥ "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះមិនត្រឹមត្រូវតាមច្បាប់ទេ។

## ហេតុដូច្នេះសម្រេច

១.ទទួលបណ្ដឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ **របរ**

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ០២ ក្រ॥ "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទី ១.គ នៃសាលក្រមព្រហ្មទណ្ឌលេខ៧១៥ "ឃ១" ក្រ॥ចុះថ្ងៃទី២១ ខែ៩ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះឡើងវិញត្រង់ចំណុចដែលត្រូវបដិសេធខាងលើ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសនាពេលសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០។

| | | |
|---|---|---|
| ឯកឧត្តម | ... | ជាប្រធាន |
| ឯកឧត្តម | ... | ជាចៅក្រម |
| ឯកឧត្តម | ... | ជាចៅក្រម |
| ឯកឧត្តម | ... | ជាចៅក្រម |
| លោកជំទាវ | .... | ជាចៅក្រម |
| កញ្ញា | ... | ជាក្រឡាបញ្ជី |

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** **ក្រឡាបញ្ជី**

.... ...